**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :០៩២ / ០០២/២០០៥

ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៦៩/០០១/២០០៥ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ធម្មនុញ្ញបន្ថែមឆ្នាំ២០០៤
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៨៣រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៥

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។* " និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា*

*ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ "* ។

ដូច្នេះសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា លេខ ១៨៣ រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៥ គឺស្របតាមរដ្ឋធម្មនុញ្ញ ។

- យល់ឃើញថា ក្នុងប្រការ ៣៣ ថ្មី វាក្យខ័ណ្ឌទី ៣ មានបទបញ្ញត្តិដែលចែងថា " ការប្រជុំនេះមិនទាមទារកូរ៉ុមទេ " ដែលត្រង់នេះ គេគួរពិចារណាទៅលើមាត្រា ៨៨ វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ដែលចែងថា : " ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល " ។ ក្នុងស្មារតីនៃប្រការ ៣៣ ថ្មី នេះ គឺ រដ្ឋសភាចង់ចោទសួររាជរដ្ឋាភិបាល ក្នុងមួយសប្តាហ៍មួយថ្ងៃ ដើម្បីជាពតិមាន ។ រដ្ឋធម្មនុញ្ញ ពុំមានបទបញ្ញត្តិណាហាមប្រជុំរបៀបនេះទេ ដូច្នេះការដាក់ពាក្យបន្ថែមដូចខាងលើ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។
- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រង់ប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែមនោះទេ ។

**សម្រេច**

**មាត្រា១.** វិសោធនកម្មនៃប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និង ប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែម ។

**មាត្រា២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន